ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ: ៤៩ ប្រ.ក

ភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពីការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវអំពីគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ

៚៚៚៚៚

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រិត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- យោងលិខិតលេខ ៨០៥ អស១.កបទ.សអ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០២ របស់ក្រសួងការបទេស និងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការអនុវត្តតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ
- យោងតំរូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សំរេច

**ប្រការ១** : បង្កើតក្រុមការងារគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ ។

**ប្រការ២ :** ក្រុមការងារគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ដែលមានសមាជិកភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក ទិត ចន្ថា | អគ្គនាយករងទេសចរណ៍ | ប្រធាន |
| ២- លោក រស់ សំអ៊ា | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក ម៉ី ម៉ារ៉ាឌី | ប្រធាននាយកដ្ឋានស្ថិតិ និងពតិមានទេសចរណ៍ | សមាជិក |
| ៤- លោក អ៊ុំ យឹម | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ៥- លោក សុខ សុគុណ | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | សមាជិក |
| ៦- លោក ជុំ សារិដ្ឋ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ | សមាជិក |
| ៧- លោក ផ្លុង ធឿន | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៨- លោក យិន ណាត | នាយកការិយាល័យមេគង្គ (GMS) | សមាជិក |

**ប្រការ៣ :** ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំផែនការការងារ កិច្ចប្រជុំ និងរបៀបវារៈនៃអង្គប្រជុំ របស់ក្រុមការងារនេះឆ្លងថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។
- ចូលរួមប្រជុំ និងធ្វើរបាយការណ៍ ជូនគណៈកម្មការសហប្រតិបត្តិការ អភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ ។
- សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្ដាក្រសួង-ខេត្ត និងអង្គការអន្តរជាតិនានា ដើម្បីគោលបំណងអភិវឌ្ឍន៍តំបន់ត្រីកោណ ។
- រៀបចំគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណទាំងពីរ ដោយធ្វើទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា សិក្សាគ្រប់លទ្ធភាពស្វែងរកប្រភពហិរញ្ញវត្ថុដើម្បីជួយដល់ការងារអភិវឌ្ឍន៍នេះ ។
- សមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយបើចាំបាច់អាចមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនាយកដ្ឋានផ្សេងទៀតចូលរួមដោយសុំយោបល់ថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។

**ប្រការ៤ :** នាយកខុទ្ទកាល័យ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អធិការ ប្រធានគ្រប់ នាយកដ្ឋាន និងសមាជិកក្រុមការងារនេះត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ល៕

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វង់ សិរីវុឌ្ឍ**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី ✓
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម

"ដើម្បីជូនជ្រាប"

- ដូចក្នុងប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ